**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

------------

# កំណត់ហេតុ
# កិច្ចប្រជុំលើកទី៥ ក្រុមប្រឹក្សាយោបល់វេជបូក

កិច្ចប្រជុំធ្វើឡើង នៅសាលប្រជុំធំរបស់រដ្ឋបាលព្រៃឈើ រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ (០៨:៣០នាទី - ១២:៣០នាទី) ក្រោមអធិបតីភាពប្រធាន លោកសៀក សុផាត (តំណាង ក្រុមប្រឹក្សាយោបល់) និងលោក គឹម សុបិន្ត ជាអ្នកសម្របសម្រួលអង្គប្រជុំ។

កិច្ចប្រជុំនេះរៀបចំឡើងដោយលេខាធិការដ្ឋានវេជបូក ដោយមានអ្នកចូលរួមសរុបចំនួន ១៥នាក់ រួមមានៈ សមាជិកក្រុមប្រឹក្សា ១៣នាក់, បុគ្គលិកលេខាធិការដ្ឋាន ២នាក់។ កិច្ចប្រជុំ គឺផ្តោតទៅលើៈ (១)ពិនិត្យ និងពិភាក្សាទៅលើអនុសាសន៍នៃជម្រើសនៃការអនុវត្តវេជបូកនៅកម្ពុជាពីបណ្តាញ NGO និង(២)ពិនិត្យទៅលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់ និងបញ្ហាផ្សេងៗ។

<u>(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធទី០១ និង០២)</u>

## មតិចាប់ផ្តើមបើកអង្គប្រជុំ

កិច្ចប្រជុំបានចាប់ផ្តើមដោយមានមតិស្វាគមន៍ និងបើកអង្គប្រជុំ ដោយសហប្រធានក្រុមប្រឹក្សាយោបល់។

លោកបណ្ឌិត សៀក សុផាត មានការសាទរចំពោះវត្តមាននៅថ្ងៃនេះ ហើយសង្ឃឹមថា កិច្ចប្រជុំក៏នឹងពិភាក្សាទៅលើរបៀបវារៈដែលបានកំណត់។

## កិច្ចប្រជុំ

(១)ពិនិត្យ និងពិភាក្សាទៅលើអនុសាសន៍ នៃជម្រើសក្នុងការអនុវត្តវេជបូកនៅកម្ពុជា ពីបណ្តាញ NGO

សមាជិកចូលរួមអង្គប្រជុំ ដោយមានការសម្របសម្រួលដោយ លោក គឹម សុបិន្ត បានធ្វើការពិនិត្យទៅលើអនុសាសន៍ដែលបានរៀបចំឡើងដោយបណ្តាញ NGO មួយចំ

នុចម្តងៗ។ អនុសាសន៍នេះ ត្រូវបានផ្ញើរជូនសមាជិកមួយចំនួនដែលប្រើប្រាស់អ៊ីម៉ែល បន្ទាប់ពីកិច្ចប្រជុំលើកទីបួនរបស់ក្រុមប្រឹក្សាយោបល់រេដបូក ដែលប្រធានមួយនោះគឺផ្តោតទៅលើជម្រើសនៃការអនុវត្តរេដបូកកម្ពុជា ដែលរួមមានៈ ជម្រើសទី១( រេដបូកផ្អែកតាមគម្រោង (Project based REDD+), ជម្រើសទី២( រេដបូកថ្នាក់ក្រោមជាតិ (Sub-national REDD+) ឬ ជម្រើសទី៣ រេដបូកថ្នាក់ជាតិ (National REDD+) ។

ជាមួយគ្នានេះដែរ កិច្ចពិភាក្សាទៅលើអនុសាសន៍ដែលបានដាក់មក គឺផ្តោតតែទៅលើពីរចំនុច ថាតើគួរអនុវត្តន៍រេដបូកថ្នាក់ជាតិ ឬ រេដបូកថ្នាក់ក្រោមជាតិ ដោយរួមមានទាំងអនុសាសន៍រួម ដែលអនុសាសន៍នីមួយៗមានដូចខាងក្រោមៈ

**ការជ្រើសរើសជម្រើរេដបូកថ្នាក់ជាតិ (National REDD+)**

១. រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវលើការកាប់បំផ្លាញព្រៃឈើ និង ការបំភាយឧស្ម័ន

២. ដោះស្រាយទូវកត្តាជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើក្នុងប្រទេសទាំងមូល ចំពោះការអនុវត្តរេដបូក ផ្អែកតាមគម្រោង ដោះស្រាយកត្តាជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើតែក្នុងកម្រិតគម្រោង

៣. កាត់បន្ថយឈ្មួញកណ្តាលក្នុងការលក់កាបូន

៤. ការផ្ទៀងផ្ទាត់ត្រូវធ្វើឡើងដោយ UNFCCC

៥. ហិរញ្ញវត្ថុរេដបូកនៅថ្នាក់ជាតិ អាចរួមវិភាគទានដល់សេចក្តីត្រូវការកម្រិតគោលនយោបាយ ដើម្បីសម្រេចលទ្ធផលនានា

៦. អ្នកផ្តល់ជំនួយ និងមូលនិធិអាកាសធាតុបៃតង (Green Climate Fund) មានបំណងគាំទ្រយ៉ាងខ្លាំង ដល់ប្រទេសមួយចំនួន ឲ្យប្តូរមកអនុវត្តន៍តាមវិធានទាំងស្រុង ដែលបានព្រមព្រៀងដោយ UNFCCC។

**ការជ្រើសរើសជម្រើសរេដបូកថ្នាក់ក្រោមជាតិៈ**

១. អនុវត្តន៍គម្រោងផ្ទាល់

២. ជម្រុញវិមជ្ឈការ

៣. គាត់យល់ច្បាស់ពីស្ថានភាព/បញ្ហានៅក្នុងសហគមន៍

៤. ជំរុញឲ្យអជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិយល់ដឹងពីរេដបូក

៥. បញ្ជ្រាបការអនុវត្តរេដបូកក្នុងផែនការអភិវឌ្ឍន៍ឃុំ/ស្រុក/ខេត្ត

៦. សង្គមស៊ីវិលអាចធ្វើការសហការណ៍ជាមួយសហគមន៍យ៉ាងជិតស្និត

៧. ការពិគ្រោះយោបល់ និងទទួលយោបល់ត្រលប់លឿន និងដោះស្រាយទាន់សភាពការណ៍

៨. មានឱកាសក្នុងការសម្រេចចិត្តពីថ្នាក់សហគមន៍បានច្រើន

៩. ការប្រើប្រាស់ថវិកាមានប្រសិទ្ធភាព និងប្រសិទ្ធផលជាង

**អនុសាសន៍រួមៈ**

១ .ត្រូវឲ្យនិយមន័យព្រៃឈើនៅក្នុងរេដបូក និងការអនុវត្តរេដបូក តែទៅលើព្រៃធម្មជាតិ

២ .ត្រូវបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងសម្បទាននានា ដែលមានការប៉ះពាល់ដល់ព្រៃធម្មជាតិ និងជីវៈចម្រុះ ។

៣ត្រូវមានយន្តការច្បាស់លាស់ និងបន្ទាន់ ក្នុងការទប់ស្កាត់ការបាត់បង់ព្រៃធម្មជាតិ . បាត់បង់ព្រៃធម្មជាតិកាន់តែកើនឡើងៗដែលបច្ចុប្បន្នការ[1]

៤ត្រូវមានយន្តការក្ន.ុងការផ្លាស់ប្តូរការអនុវត្តរេដបូក ផ្អែកតាមគម្រោងទៅរេដបូកថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ

៥ត្រូវគាំទ្រគម្រោងសាកល្បងរេដបូក សម្រាប់ជាបទពិសោធន៍ និងជាមេរៀន ក្នុងការ . អនុវត្តរេដបូកថ្នាក់ជាតិ។

៦ថ្នាក់ជាតិ ត្រូវមានការចូលរួមពីគយន្តការការអនុវត្តរេដបូក .្រប់ភាគីពាក់ព័ន្ធ និងត្រូវឲ្យអង្គការសង្គមស៊ីវិលចូលរួមតាមដានការអនុវត្តកម្មវិធីរេដបូក។

៧ត្រូវឲ្យអង្គការសង្គមស៊ីវិលចូលគ្រប់ដំណាក់កាល និងពេញលេញ .

៨ដល់ភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវផ្តល់ចំណេះដឹងអំពីរេដបូក .

៩ត្រូវផ្តល់ទៅឲវិភាគទានក្នុងការអនុវត្តរេដបូក .ឲ្យថ្នាក់ក្រោមជាតិ និងសហគមន៍ ឲ្យបានច្រើនជាង នូវថ្នាក់ជាតិ ។

១០ .បញ្ជ្រាបការអនុវត្តរេដក្នុងផែនការអភិវឌ្ឍឃុំ/ស្រុក/ខេត្ត

១១ការទទួលផលពីការអនុវត្តកម្មវិធីរេដបូក ត្រូវតែផ្តល់ .ទៅឲ្យប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

---

[1] ព្រៃឈើក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៣ មាន៧២.១១ ភាគរយ នៃផ្ទៃប្រទេស ដល់ ២០១៣ នៅសល់តែ ៤៦.៣៣ភាគរយ http://www.opendevelopmentcambodia.net/briefings/forest-cover/

១២ .ព័ត៌មានក្នុងការអនុវត្តកម្មវិធីរេដបូក ត្រូវតែចែករំលែកទៅភាគីពាក់ព័ន្ធជាសាធារណៈ រួមទាំង ព័ត៌មានថវិកា។

១៣កម្មវិធីរេដបូកត្រូវតែមានតម្លាភាព .

១៤លំហូរព័ត៌មានច្បាស់លាស់ រួមទាំងលំហូរថវិកា។ត្រូវមានយន្តការតាមដាន និង .

(អនុសាសន៍កែសម្រួលសូមអានឧបសម្ព័ន្ធទី០៣)

**ការពិនិត្យ និងពិភាក្សា៖**

លោក គីម សុបិន្ត៖ បានធ្វើការសាកសួរសមាជិកម្តងមួយចំនុចៗ ជាមួយនឹងការផ្តល់មតិយោបល់ និងកែសម្រួល។

លោកស្រី ហ៊ូ កល្យាណ៖ ទៅលើអនុសាសន៍រួមចំនុចទី១ តើយើងគួរតែផ្តោតតែទៅលើព្រៃធម្មជាតិ ឬក៏ គួរបញ្ចូលព្រៃផ្សេងៗទៀត?

សមាជិកមួយចំនួន៖ បានគិតថាគួរតែពិចារណាទៅលើព្រៃដាំ ឬ ស្តារឡើងវិញ ពីព្រោះប្រសិនបើផ្តោតតែទៅលើព្រៃធម្មជាតិនោះ រេដបូកគឺមិនអាចអនុវត្តន៍បានប្រសើរនោះទេ ដោយសារតែការមិនអាចធានាឲ្យបាននូវការការពារព្រៃធម្មជាតិពីការកាប់បំផ្លាញខុសច្បាប់។

លោក សៀក សុផាត៖ បើយោងទៅតាមអនុសាសន៍រួមចំនុចទី៦ និងទី៧ យើងគួរតែពិចារណា ថាតើគួរមានតែសង្គមស៊ីវិលជាអ្នកចូលរួមតាមដានអង្កេត ឬក៏ គួរឲ្យមានសមាជិកចូលរួមអង្កេតទៅតាមជំនាញ?

សមាជិកភាគច្រើន បានសំណូមពរឲ្យមានការចូលរួមទាំងអស់គ្នា ហើយនឹងធ្វើពិភាក្សា និងពិចារណាជាមួយក្រុមរបស់ខ្លួននីមួយៗ ថាតើគួរតែចូលរួមតាមផ្នែក ឬ តាមជំនាញ យ៉ាងណានោះ។

កញ្ញា គេង រិទ្ធីនី និងលោក សារ ថៃ៖ យើងគួរចូលរួមតាមដាន និងអនុវត្តន៍រេដបូក គ្រប់ដំណាក់ និងពេញលេញ ដោយសារការចូលរួមដឹងឮ គឺមិនចាំបាច់ត្រូវតែមានជំនាញនោះទេ។

លោក សៀក សុផាត៖ ដោយសារសមាជិកភាគច្រើន ទើបបានពិនិត្យមើលឯកសារនៅថ្ងៃនេះ និងមិនទាន់បានពិភាក្សាជាមួយក្រុមរបស់ខ្លួន និងដោយសារឯកសារនេះ គឺបានធ្វើឡើងតែពីតំណាងបណ្តាញក្រុមNGOតែមួយប៉ុណ្ណោះ។ ដូច្នេះ លោក សុំ

ឲ្យសមាជិកតំណាងក្រុមប្រឹក្សាយោបល់ទាំងអស់ គឺការយលមតិយោបល់ និងអនុសាសន៍ទាំងនេះ ទៅលើពិភាក្សាជាមួយក្រុមរបស់ខ្លួន ហើយផ្ញើនូវមតិយោបល់របស់ក្រុមដែលខ្លួនតំណាង មកលេខាធិការដ្ឋានវេជបូក ដើម្បីធ្វើដាក់បញ្ចូលគ្នាមុនកិច្ចប្រជុំពិភាក្សាលើក្រោយ ប្រសិនបើមាន មុនពេលដាក់បញ្ជូនអនុសាសន៍ទាំងនេះទៅជូនក្រុមការងារវេជបូក ដើម្បីធ្វើការពិចារណា។

**(២)ពិនិត្យទៅលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់**

ការពិភាក្សា បានធ្វើឡើងដោយមានការសម្របសម្រួលដោយ លោក គឹម សុបិន្ត និងបានពិនិត្យទៅលើជំពូកចំនួន៤ ដូចខាងក្រោម៖

ជំពូកទី១ សាវតានៃកម្មវិធីវេជបូកកម្ពុជា និងក្រុមប្រឹក្សាយោបល់

ជំពូកទី២ គោលបំណងនៃក្រុមប្រឹក្សាយោបល់

ជំពូកទី៣ វចនាសម្ព័ន្ធ និងការគ្រប់គ្រងនៃក្រុមប្រឹក្សាយោបល់

ចំពោះជំពូកចំនួនប្រាំដែលនៅសល់នោះ នឹងធ្វើការពិភាក្សានៅក្នុងអង្គប្រជុំលើកទី៦ ដែលជំពូកទាំងនោះរួមមាន៖

ជំពូកទី៤ តួនាទីនៃសហប្រធាន និងសមាជិកនៃក្រុមប្រឹក្សាយោបល់

ជំពូកទី៥ តួនាទីនៃលេខាធិការដ្ឋានវេជបូកកម្ពុជានៅក្នុងក្រុមប្រឹក្សាយោបល់

ជំពូកទី៦ យន្តការនៃការលំហូរព័ត៌មាន និងផែនការអនុវត្តន៍របស់ក្រុម

ជំពូកទី៧ ហិរញ្ញវត្ថុ និងការរក្សាកំណត់ត្រា

ជំពូកទី៨ ការធ្វើវិសោធនកម្មលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងការរំលាយនៃក្រុមប្រឹក្សាយោបល់

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធទី០៤)

***ការសម្រេច៖***

១. សមាជិកទៅយកអនុសាសន៍ទៅពិភាក្សាជាមួយក្រុមរបស់ខ្លួន ហើយធ្វើការផ្ញើនូវយោបល់បន្ថែមទាំងនោះមកលេខាធិការដ្ឋាន ដើម្បីធ្វើការបូកបញ្ចូលសម្រាប់ការពិភាក្សាក្នុងកិច្ចប្រជុំលើកទី៦បន្ទាប់។

២. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់ ដែលនៅសល់ នឹងធ្វើការពិភាក្សាក្នុងអង្គប្រជុំលើកក្រោយ។

៣. **កិច្ចប្រជុំលើកទី៦ គឺនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤** ដែលនឹងបន្តពិភាក្សាទៅលើរបៀបវារៈ រួមមាន៖ (១)អនុសាសន៍ពីតំណាងក្រុមប្រឹក្សាយោបល់នីមួយៗ, (២) លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់, (៣)បទពិសោធន៍ និងការជួបប្រទះរបស់សមាជិកក្រុម , (៣)ការពិនិត្យទៅលើរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមការងាររេដបូក និងបញ្ហាផ្សេងៗ។

**សរុបនៃអង្គប្រជុំ**

សហប្រធាន លោក សៀក សុផាត សូមអរគុណចំពោះលោក គីម សុបិន្ត ដែលបានធ្វើការសម្របសម្រួលអង្គប្រជុំ ហើយក៏សូមអរគុណសមាជិកក្រុមប្រឹក្សាដែលក្នុងការចូលរួមក្នុងកិច្ចប្រជុំនេះ ហើយសង្ឃឹមថាក្រុមនឹងបន្តការចូលរួមកិច្ចប្រជុំ និងការពិភាក្សាឲ្យបានសកម្ម និងប្រសើរឡើងដូចថ្ងៃនេះ។

**អ្នកធ្វើកំណត់ហេតុ**

**ប្រធានក្រុមប្រឹក្សាយោបល់**

# កិច្ចប្រជុំលើកទី៤ក្រុមការងាររេដ+កម្ពុជា

**ទីកន្លែងប្រជុំ:** សណ្ឋាគារ៉ាហ្វល់ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ

**កាលបរិច្ឆេទ:** ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ (២:៣០-៥:១៥នាទី រសៀល)

## របៀបវារៈកិច្ចប្រជុំ

| | | |
|---|---|---|
| ០២:០០-០២:៣០ | ចុះឈ្មោះអ្នកចូលរួម | - មន្ត្រីលេខាធិការដ្ឋាន |
| ០២:៣០-០២:៤០ | **<u>បើកអង្គប្រជុំ</u>**<br>- មតិចាប់ផ្តើមបើកអង្គប្រជុំ | <br>- ប្រធានអង្គប្រជុំ |
| ០២:៤០-០៣:០០ | **<u>វឌ្ឍនភាពនៃការសម្រេចក្នុងកិច្ចប្រជុំលើកទី៣</u>**<br>- ឯកសារសង្ខេបការសម្រេចរបស់ COP ស្តីពីរេដ<br>- ការបង្ហាញថវិកាប្រចាំឆ្នាំ២០១៤របស់UN-REDD<br>- លិខិតសុំចាត់បញ្ជូនមន្ត្រីចូលជាសមាជិកក្រុមបច្ចេកទេស | <br>- ធី ហៀង<br>- ប៉ាន់ធីតា<br>- លន់គឹមហ៊ី |
| ០៣:០០-០៣:៤០ | **<u>បច្ចុប្បន្នភាពកម្មវិធីរេដ+នៅកម្ពុជា</u>**<br><u>សមាសភាគទី១</u><br>- អនុសាសន៍នៃការវាយតម្លៃពាក់កណ្តាលអាណត្តិ CAM-REDD<br>- សិក្ខាសាលាចាប់ផ្តើមគម្រោង FCPF<br>- ការបង្កើតក្រុមយេនឌ័រ<br><u>សមាសភាគទី២</u><br>- កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តស្តីពីការចែករំលែកផលប្រយោជន៍<br><u>សមាសភាគទី៤</u><br>- ការបណ្តុះបណ្តាលស្តីពីការចុះធ្វើសារពើភណ្ឌនៅទីវាល<br>- សិក្ខាសាលាស្តីពីមូលហេតុដែលនាំឲ្យបាត់បង់ព្រៃឈើ | <br><br>- Hiroshi Nakata<br>- Moeko Saito Jensen<br>- ធី ហៀង<br><br>- លន់គឹមហ៊ី<br><br>- ឡេង ជីវិន<br>- ហ្វូលឹមឈុន |
| ០៣:៤០-០៥:០០ | **<u>ប្រធានបទពិភាក្សា</u>**<br>- យន្តការថវិការេដ+ និងការងារបន្តក្រោយពីបញ្ចប់របាយការណ៍សិក្សា<br>- ការបង្ហាញពីឯកសាទស្សនទានយុទ្ធសាស្ត្ររេដ+កម្ពុជា<br>- ការបង្ហាញពីការងារសារពើភ័ណ្ឌព្រៃឈើជាតិនិងនិយមន័យព្រៃឈើ<br>- បញ្ហាផ្សេងៗ | <br>- ឈុន ឌីលុច<br>- Peter Iversen<br>- Mathieu VanRijn |
| ០៥:០០-០៥:២០ | **<u>បិទអង្គប្រជុំ</u>**<br>- មតិបូកសរុប និងបិទអង្គប្រជុំ<br>- ការថតរូបជាក្រុម | <br>- ប្រធានអង្គប្រជុំ |
| ០៥:២០-០៥:៤០ | សម្រាកអាហារសម្រន់ | |

The Third Meeting of the fourth REDD+ Taskforce

Place: Raffle Hotel le Royal Phnom Penh
Date: 28 March 2014 (02:30 - 05:30 pm)

**Agenda**

| | | |
|---|---|---|
| 02:00 - 02:30 | Registration | RTS staff |
| 02:30 - 02:40 | **<u>Open session</u>**<br>❖ Opening Remark | - Chair of meeting |
| 02:40 – 03:00 | **<u>Progress against decision in the 3rd Taskforce meeting</u>**<br>❖ UNFCCC COP decisions on REDD+ with summary<br>❖ AWP UN-REDD programme<br>❖ Letter to MRD to nominate staff for Technical Team | - Ms. Thy Heang<br>- Ms. Pan Thida<br>- Mr. Lun Kimhy |
| 03:00 - 03:40 | **<u>Update REDD+ programme since the 3rd Taskforce meeting</u>**<br><u>Component 1</u><br>❖ CAM-REDD Midterm evaluation recommendations<br>❖ FCPF inception workshop<br>❖ Gender group establishment<br><u>Component 2</u><br>❖ Benefit sharing consultation meeting at provinces<br><u>Component 4</u><br>❖ Training on NFI field manual<br>❖ Workshop on drivers of deforestation and forest degradation | - Mr. Hiroshi Nakata<br>- Ms. Moeko Saito Jensen<br>- Ms. Thy Heang<br>- Mr. Lun Kimhy<br>- Mr. Leng Chivin<br>- Mr. Hour Lim Chhun |
| 03:40 - 05:00 | **<u>Topics for Discussion</u>**<br>❖ Next steps on REDD+ Fund following the final report received (suggest decision on further work)<br>❖ REDD+ Strategy (concept paper and presentation)<br>❖ National Forest Inventory (concept paper and presentation) and Forest definition<br>❖ Other issues | - Mr. Chhun Delux<br>- Mr. Peter Iversen<br>- Mr. Mathieu VanRijn |
| 05:00 – 05:20 | **<u>Closed session</u>**<br>❖ Closing Remark<br>❖ Group Photo | - Chair of meeting |
| 05:20 - 05:40 | <u>Break and standing reception</u> | |

**មូលនិធិ REDD+**

ឯកសារពិភាក្សាសម្រាប់ក្រុមការងារពិសេស **REDD+** សម្រាប់របាយការណ៍សំយោគ៖ ការវាយតម្លៃយន្តការមូលនិធិដែលមានស្រាប់នៅក្រោមច្បាប់កម្ពុជាសម្រាប់មូលនិធិជាតិ REDD+ ដោយ Gillian Duggin.

ក្នុងចំណោមជម្រើសទាំងបួនដែលទីប្រឹក្សាបានវាយតម្លៃ៖

ជម្រើស ១៖ មូលនិធិត្រឹះពហុម្ចាស់ជំនួយ ដែលចាត់ចែងដោយស្ថាប័នឯករាជ្យមួយ

ជម្រើស ២៖ មូលនិធិជាតិ REDD+ ចាត់ចែងដោយរដ្ឋាភិបាល ដែលបង្កើតឡើងតាមរយៈច្បាប់ថ្មីមួយ

ជម្រើស ៣៖ មូលនិធិរង REDD+ មួយ ឬ យន្តការផ្តល់មូលនិធិនៅក្នុងមូលនិធិជាតិប្រែប្រួលអាកាសធាតុថ្មីមួយ

ជម្រើស ៤៖ វិសោធនកម្ម និងការពង្រីកប្រការនានាស្តីពីមូលនិធិនៅក្នុងច្បាប់ស្តីពីព្រៃឈើឬច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

ជម្រើស ១ ត្រូវបានចាត់ទុកថាជាជម្រើសសមស្របបំផុត ដោយអាចទាញហេតុផលថាជម្រើសនេះ ដែលជាអង្គភាពមួយនៅថ្នាក់ជាតិ ទំនងបំផុតថាអាចទ្រទ្រង់លទ្ធភាពទទួលបានហិរញ្ញវត្ថុអន្តរជាតិ ដោយធ្វើឲ្យមានតុល្យភាពការគ្រប់គ្រងនៃអ្នកពាក់ព័ន្ធនានាជាមួយភាពម្ចាស់ការរបស់ជាតិ។ ជម្រើសនេះទំនងជាបង្កើតទំនុកចិត្តក្នុងចំណោមម្ចាស់ជំនួយ ដើម្បីរួមវិភាគទានទៅក្នុងមូលនិធិ REDD+ និងអាចឲ្យមានការពិសោធន៍ជាមួយគំរូនានាដែលមានលក្ខណៈជាក់លាក់សម្រាប់កាលៈទេសៈរបស់កម្ពុជា ដោយគ្មានការភ្ជាប់ទៅនឹងយន្តការមិនសមស្របណាមួយនៅពេលមិនទាន់ឈានដល់ដំណាក់កាលសមស្រប ទន្ទឹមនឹងគាំទ្រដល់ការកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងមូលនិធិ។ វាក៏ទំនងបំផុតជាអាចបង្កើតបានយ៉ាងឆាប់រហ័ស និងអាចផ្ទេរទៅក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាលទៅអនាគតផងដែរ តាមរយៈការបញ្ចូលទៅក្នុងមូលនិធិជាតិប្រែប្រួលអាកាសធាតុ ឬបង្កើតឡើងតាមរយៈច្បាប់ថ្មីមួយ។

ទន្ទឹមនឹងនេះ មានការស្នើឲ្យបង្កើតក្រុមការងារ(ឬក្រុមប្រហែលគ្នានេះ)មួយ ដើម្បីដឹកនាំដំណើរការពិស្តារនៃការគិតគូរ និងបង្កើតមូលនិធិជាតិ REDD+ ដែលរួមទាំងដំណើរការសមស្របនៃការចូលរួម និងការពិគ្រោះយោបល់ផងដែរ។

សំណួរសម្រាប់ក្រុមការងារពិសេសនេះ

១) តើក្រុមការងារពិសេសនេះឯកភាពក្នុងការបង្កើតក្រុមការងារមូលនិធិ REDD+ បែបនេះមួយដែរឬទេ ដែលទំនងបំផុតថាត្រូវរួមបញ្ចូលសមាជិកមកពីស្ថាប័នមិនមែនរដ្ឋាភិបាល?

២) តើក្រុមការងារពិសេសឯកភាពថា លេខាធិការដ្ឋាននៃក្រុមការងារពិសេសនេះរៀបចំឯកសារគោលគំនិតមួយស្តីពីការបង្កើតមូលនិធិត្រឹះពហុម្ចាស់ជំនួយ (ជម្រើស ១)ដែរឬទេ? ឯកសារគោលគំនិតនេះត្រូវរួមបញ្ចូលការគិតគូរអំពីរបៀបដោះស្រាយចំណុចនានាដែលមានចែងខាងក្រោម និងអាចចំណុចបន្ថែមនានាដែលកំណត់ឃើញនៅក្នុងដំណើរការនេះផងដែរ។

a. លក្ខខណ្ឌប្រតិបត្តិសម្រាប់មូលនិធិនេះចែងអំពីសំណុំលក្ខណៈសំខាន់ៗ និងទំនាក់ទំនងជាមួយអង្គភាពជាតិដទៃទៀតដែលធ្វើការទាក់ទងនឹង REDD+

b. ផែនការវិនិយោគឬសេចក្តីអធិប្បាយអំពីសំណុំរឿង(ក្របខ័ណ្ឌលទ្ធផល) ដែលផ្អែកលើយុទ្ធសាស្ត្រជាតិ REDD+ ដែលរួមទាំង ក្របខ័ណ្ឌមួយសម្រាប់បង្កើតការទូទាត់ទៅតាមគុណផល/លទ្ធផល

ទាំងសម្រាប់សូចនាករគោលនយោបាយ និងស្ថាប័ន បន្ថែមលើការផ្តល់មូលនិធិដែលផ្អែកលើសកម្មភាពសម្រាប់កាត់បន្ថយការបំភាយធៀបនឹងលក្ខខណ្ឌគោលរបស់ជាតិដែលបានកំណត់។

c. ឯកសារណែនាំប្រតិបត្តិការ ដែលរួមទាំង

i. សមាសភាព និងតួនាទីរបស់ក្រុមប្រឹក្សាភិបាល ដែលរួមទាំង សមាជិកអន្តរវិស័យមកពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងតំណាងពីវិស័យមិនមែនរដ្ឋាភិបាល (ដូចជា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល)
ii. សមាសភាព និងតួនាទីរបស់លេខាធិការដ្ឋាន ដែលអាចតាំងនៅក្នុងគ្រឹះស្ថានណាមួយរបស់រដ្ឋាភិបាល (ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
iii. ការកំណត់អត្តសញ្ញាណគ្រឹះស្ថានពហុភាគីដើម្បីដើរតួជាស្ថាប័នគ្រប់គ្រងជំនួស (ដែលរួមទាំង ការធ្វើសេចក្តីសម្រេចអំពីគំរូគ្រប់គ្រងមូលនិធិនេះផងដែរ)
iv. សមាសភាពនិងតួនាទីរបស់គណៈកម្មាធិការបច្ចេកទេស ដែលមានអ្នកជំនាញការ (រួមទាំងអ្នកមកពីខាងក្រៅស្ថាប័នរដ្ឋាភិបាល) ដើម្បីផ្តល់យោបល់ដល់ក្រុមប្រឹក្សានេះអំពីគោលនយោបាយ និងសេចក្តីសម្រេចដែលផ្អែកលើសកម្មភាព
v. លក្ខណៈបច្ចេកទេសសម្រាប់ស្តង់ដារអន្តរជាតិដែលទាក់ទងនឹងការចាត់ចែងរចនាសម្ព័ន្ធសម្រាប់ការធានា និងការប្តេជ្ញាចំពោះប្រព័ន្ធសុវត្ថិភាពសង្គមនិងបរិស្ថាន
vi. គំរូសម្រាប់ការទទួលមូលនិធិ
vii. យន្តការសម្រាប់ការផ្តល់មូលនិធិ
viii. វិភាជន៍មូលនិធិ និងនីតិវិធីជ្រើសរើសសំណើ
ix. ជាតុផ្សំសំខាន់ៗនៃការពិនិត្យតាមដាននិងវាយតម្លៃ នៅកម្រិតមូលនិធិ និងគម្រោង ដែលរួមទាំងការវាយតម្លៃនិងសវនកម្មដោយស្ថាប័នពីខាងក្រៅ និងចំណងទាក់ទងជាមួយឧបករណ៍/យន្តការ REDD+ ដែលពាក់ព័ន្ធ ដូចជា NFMS, SIS, ការចុះបញ្ជី។ល។
x. រចនាសម្ព័ន្ធបណ្តោះអាសន្ន ប្រសិនបើចាំបាច់។

**d.** ផែនការរៀងគរមូលនិធិ និងផែនការធុរកិច្ច

**e.** លក្ខខណ្ឌប្រតិបត្តិសម្រាប់បុគ្គលិកនិងអ្នកជំនាញការដែលត្រូវជួលមកធ្វើការ

**f.** ផែនការពិនិត្យតាមដាន និងវាយតម្លៃ (**M&E)**

**g.** ផែនការគ្រប់គ្រងហានិភ័យ

**h.** ការវិភាគដៃគូ និងសកម្មភាពនានា

**i.** កិច្ចព្រមព្រៀងតាមផ្លូវច្បាប់រវាងម្ចាស់ជំនួយ និងមូលនិធិនេះ និងមូលនិធិនេះជាមួយអង្គភាពនានាដែលទទួលការគាំទ្រពីមូលនិធិនេះ

**j.** ការកសាងសមត្ថភាព និងផែនការអន្តរកាល

# ឯកសារគោលគំនិត

## កម្មវិធីការងារសម្រាប់បង្កើតយុទ្ធសាស្ត្រជាតិ **REDD+**

## សាវតា

យុទ្ធសាស្ត្រជាតិ REDD+ ត្រូវបានកត់សំគាល់នៅក្នុងសេចក្តីសម្រេចមួយចំនួនរបស់UNFCCC ថាជាលក្ខខណ្ឌគន្លឹះមួយសម្រាប់ការចូលរួមនៅក្នុងយន្តការអន្តរជាតិ REDD+ ដូចជា វាក្យខណ្ឌ ៧១ នៃកិច្ចព្រមព្រៀងកាន់គុន បានស្នើឲ្យប្រទេសនានាបង្កើតៈ

1. យុទ្ធសាស្ត្រជាតិ REDD+ ឬផែនការសកម្មភាពមួយ
2. កម្រិតបំភាយយោងព្រៃឈើជាតិ និង/ឬ កម្រិតយោងព្រៃឈើ (ឬថ្នាក់ក្រោមជាតិ)
3. ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិដែលម៉ត់ចត់និងមានតម្លាភាពសម្រាប់ការពិនិត្យតាមដាននិងរាយការណ៍អំពីសកម្មភាព REDD+
4. ប្រព័ន្ធមួយសម្រាប់ផ្តល់ព័ត៌មានអំពីថាតើប្រព័ន្ធសុវត្ថិភាពដែលមានយោងនៅក្នុងឧបសម្ព័ន្ធ I នៃសេចក្តីសម្រេចនេះ ត្រូវបានដោះស្រាយ និងគោរពដែរឬទេ។

សេចក្តីសម្រេចអំពីហិរញ្ញវត្ថុ REDD+ លេខ 9/CP.19 ពី COP19 វាក្យខណ្ឌ 3 អំពាវនាវឲ្យភាគីប្រទេសកំពុងអភិវឌ្ឍន៍ អនុវត្តសកម្មភាពដែលផ្អែកលើលទ្ធផល ដូចមានយោងនៅក្នុងសេចក្តីសម្រេច 1/CP.16, វាក្យខណ្ឌ 73, ដើម្បីស្វែងរក និងទទួល ហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល ហើយសកម្មភាពទាំងនោះត្រូវតែអាចវាស់បាន រាយការណ៍បាន និងផ្ទៀងផ្ទាត់បានពេញលេញ អនុលោមតាមសេចក្តីសម្រេច -13/CP.19 និង 14/CP.19, ហើយភាគីប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែដាក់ឲ្យអនុវត្តប្រការទាំងអស់ដែលយោងនៅក្នុងសេចក្តីសម្រេច 1/CP.16, វាក្យខណ្ឌ 71, អនុលោមតាមសេចក្តីសម្រេច 12/CP.17 និង 11/CP.19។

គេពុំទំនងជាមានការណែនាំបន្ថែមទៀតពី UNFCCC សម្រាប់យុទ្ធសាស្ត្រជាតិ REDD+ ឡើយ។

ផែនទីបង្ហាញផ្លូវ REDD ទោះបីនៅពុំទាន់បានអនុម័តជាផ្លូវការក្តី រួមមាន សេចក្តីព្រាងយុទ្ធសាស្ត្រ REDD+។ ការបង្កើតយុទ្ធសាស្ត្រជាតិ REDD+ អាចទាញយកប្រយោជន៍ពីកិច្ចការពីខាងដើម។

គោលដៅនៃការបង្កើតយុទ្ធសាស្ត្រជាតិ REDD+ គឺដើម្បីកម្ពុជាត្រៀមលក្ខណៈចូលរួមនៅក្នុងយន្តការហិរញ្ញប្បទាន **REDD+** កំណត់អត្តសញ្ញាណសកម្មភាពនានាដែលចាំបាច់ដើម្បីបង្កើតលទ្ធផល នៅក្នុងលក្ខខណ្ឌនៃការកាត់បន្ថយការបំភាយ ឬ បង្កើនសម្រូប ឧស្ម័នផ្ទះកញ្ចក់ ក៏ដូចជា ការអនុវត្តសកម្មភាពដែលបានកំណត់អត្តសញ្ញាណ និងដោះស្រាយទិដ្ឋភាពចាំបាច់ដទៃទៀតសម្រាប់ ការចូលរួមនៅក្នុងយន្តការអន្តរជាតិនៃ UNFCCC REDD+ផងដែរ។

យុទ្ធសាស្ត្រជាតិ **REDD+** ត្រូវចែងសម្រាប់ប្រទេសទាំងមូល និងមានសារៈសំខាន់ដើម្បីសម្រេចលទ្ធផលនៅកម្រិតប្រទេស ដែលអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើនត្រូវតែពាក់ព័ន្ធនិងធ្វើការឆ្ពោះទៅសម្រេចគោលដៅរួម។

យុទ្ធសាស្ត្រមួយគួរតែផ្តល់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស ក្រសួង និងស្ថាប័នពាក់ព័ន្ធនានាដែល ធ្វើសេចក្តីសម្រេចគោលនយោបាយសំខាន់ៗអំពីការប្រើប្រាស់ដី ដែលរួមទាំង ព្រៃឈើផងដែរ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រមួយគួរតែមាននាទីជាឧបករណ៍មួយដើម្បីប្រាស្រ័យទាក់ទងទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាទៅកាន់អ្នកពាក់ព័ន្ធនានា ក៏ដូចជាម្ចាស់ជំនួយអន្តរជាតិ ដែលជាមធ្យោបាយដើម្បីទាក់ទាញហិរញ្ញវត្ថុផងដែរ។

ការបង្កើតយុទ្ធសាស្ត្រជាតិ ទាមទារឲ្យមានការពាក់ព័ន្ធនៃអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ខេត្ត និងថ្នាក់ជាតិ ក៏ដូចជា សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ និងត្រូវដឹកនាំដោយក្រុមការងារពិសេសREDD+ជាតិ ដែលគាំទ្រដោយការងារបច្ចេកទេស ដែលអនុវត្ត

ដោយក្រុមបច្ចេកទេសចំនួនបួន ការផ្តល់យោបល់បន្ថែមពីក្រុមពិគ្រោះយោបល់ និងគាំទ្រដោយលេខាធិការដ្ឋាននៃក្រុមការងារពិសេស REDD+ ក៏ដូចជា ពីសំណាក់ក្របខ័ណ្ឌគាំទ្រមួយចំនួនផងដែរ។

រចនាសម្ព័ន្ធស្ថាប័ន និងក្រុមបច្ចេកទេស ជាអ្នកផ្តល់ភាគច្រើននូវយោបល់បច្ចេកទេស ទៅក្នុងការរៀបចំយុទ្ធសាស្ត្រនេះ ហើយក្រុមការងារពិសេស REDD+ ជាតិ ត្រូវពិចារណាអនុសាសន៍ និងធ្វើសេចក្តីសម្រេចនានាដែលពាក់ព័ន្ធ។

ការអនុម័តយុទ្ធសាស្ត្រជាតិ REDD+ នៅក្នុងដំណាក់កាលណាមួយ នឹងធ្វើទៅតាមនីតិវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងធានាការបន្សុីគ្នាជាមួយគោលនយោបាយពាក់ព័ន្ធផ្សេងទៀត។

ខ្លឹមសារនៃយុទ្ធសាស្ត្រជាតិ **REDD+**

យុទ្ធសាស្ត្រជាតិ REDD+ អាចរួមបញ្ចូលជាតុ/ជំពូកនានាដូចខាងក្រោម អនុលោមតាមលក្ខខណ្ឌរបស់ UNFCCC និងត្រូវធានាថា វារួមបញ្ចូលជាតុផ្សំដែលពាក់ព័ន្ធនានាសម្រាប់ការអនុវត្ត REDD+ ឲ្យបានជោគជ័យ។

- គោលបំណងនៃយុទ្ធសាស្ត្រនេះ – ប្រការនេះគួរតែរួមបញ្ចូលចំណុចដៅមួយ (ដែលវាស់ជាបរិមាណកាត់បន្ថយ $CO_2$ គិតជាតោន រហូតដល់ឆ្នាំ 20XX)– នេះជាប្រការដែលមានប្រយោជន៍សម្រាប់ទាក់ទាញការគាំទ្រពីម្ចាស់ជំនួយនានាបន្ថែមទៀត
- សាវតាអំពីកម្ពុជា វិស័យព្រៃឈើ ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ផែនការនិងយុទ្ធសាស្ត្រដែលមានស្រាប់ ដែលរួមទាំង អាចជាចំណុចដៅ សារៈសំខាន់ខាងសេដ្ឋកិច្ច និងបរិស្ថាននៃវិស័យព្រៃឈើ និងព័ត៌មាន អំពីបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើផងដែរ[1]
- ការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ ដែលរួមទាំង ការទទួលខុសត្រូវ និងសមត្ថកិច្ចសម្រាប់គ្រប់ចំណុចនានាដែលបានកត់សំគាល់ខាងក្រោម ដូចជា ប្រព័ន្ធសុវត្ថិភាព ការពិនិត្យតាមដានព្រៃឈើជាតិ ហិរញ្ញវត្ថុ។ល។
- គោលនយោបាយ និងវិធានការនានាដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (គោលនយោបាយ និងវិធានការនានា គួរតែពង្រឹងជាបន្ថែមនូវច្បាប់ និងគោលនយោបាយនានាដែលមានស្រាប់ ពីសំណាក់ស្ថាប័នទទួលខុសត្រូវ)[2]
- ប្រព័ន្ធជាតិមួយដើម្បីដោះស្រាយប្រព័ន្ធសុវត្ថិភាព ដែលរួមទាំង ដំណើរការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនានាទាំងអស់ និងផ្តល់ព័ត៌មានអំពីថាតើនឹងដោះស្រាយនិងគោរពតាមប្រព័ន្ធសុវត្ថិភាពដោយរបៀបណា[3]
- ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិដែលមានលក្ខណៈម៉ត់ចត់និងមានតម្លាភាព ដើម្បីអាចរាយការណ៍អំពីការបំភាយ និងសម្រូបពីសកម្មភាព REDD+[4]
- កម្រិតយោងព្រៃឈើជាតិ ឬ កម្រិតបំភាយយោងព្រៃឈើ[5]
- ប្រព័ន្ធជាតិមួយសម្រាប់រាយការណ៍អំពីការបំភាយឧស្ម័នផ្ទះកញ្ចក់ អនុលោមតាមគោលការណ៍ណែនាំរបស់ IPCC ដែលរួមទាំង ការត្រួតពិនិត្យគុណភាព និងនីតិវិធីធានាគុណភាពផងដែរ[6]

---

[1] សេចក្តីសម្រេច 14/CP.19 ស្តីពី MRV ពី COP19, វាក្យខណ្ឌ 9 ផ្តល់សេចក្តីយោងដោយប្រយោលអំពីតម្រូវការឲ្យដាក់ជូនព័ត៌មានអំពីបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងមធ្យោបាយដើម្បីដោះស្រាយ.

[2] ចំណុចនេះអាចរាប់បញ្ចូលកំណែទម្រង់ច្បាប់ខ្លះៗ ប្រសិនបើចាំបាច់.

[3] សេចក្តីសម្រេច 1/CP.16, 12/CP.17 និងសេចក្តីសម្រេចរបស់ COP19 ស្តីពីប្រព័ន្ធសុវត្ថិភាព សុទ្ធតែផ្តល់ការណែនាំអំពីប្រការនេះ។

[4] សេចក្តីសម្រេច 4/CP.15, 1/CP.16 និងសេចក្តីសម្រេច 11/CP.19 របស់ COP19 ស្តីពីប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ ផ្តល់ការណែនាំអំពីចំណុចនេះ

[5] សេចក្តីសម្រេច 5/CP.15, 1/CP.16, 12/CP17, 13/CP.19 និង 14/CP.19 សុទ្ធតែផ្តល់ការណែនាំពាក់ព័ន្ធសម្រាប់ចំណុចនេះ

[6] សេចក្តីសម្រេច 14/CP.19 ស្តីពី MRV មានសេចក្តីយោងទៅសេចក្តីសម្រេច 2/CP.17, ឧបសម្ព័ន្ធ III ស្តីពីការធ្វើបច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្តង និងឧបសម្ព័ន្ធបច្ចេកទេស ផ្តល់ការណែនាំអំពីចំណុចនេះ សូម្បីពុំមានការចែងបញ្ជាក់ទៅ REDD+ ក៏ដោយ។

- មូលនិធិជាតិដើម្បីទទួល និងផ្ទេរការទូទាត់សម្រាប់ REDD+[7]
- ប្រព័ន្ធចែកផលនៅថ្នាក់ជាតិ
- អាចមានសេចក្តីអធិប្បាយខ្លះៗអំពីទំនាក់ទំនងជាមួយការអនុវត្តនៅថ្នាក់ក្រោមជាតិ។
- ការផ្តល់មូលនិធិសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ – យុទ្ធសាស្ត្រគួរតែមានភ្ជាប់ជាមួយផែនការសកម្មភាពមួយចំនួន ដូចជាផែនការសកម្មភាពនៃស្ថាប័នពាក់ព័ន្ធសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ជាមួយចំណុចគោលច្បាស់លាស់ និងថ្លៃចំណាយ។ ទោះបីការអនុវត្តផែនការសកម្មភាពគួរតែបានទទួលហិរញ្ញវត្ថុគាំទ្រពីយន្តការ REDD+ ដែលផ្អែកលើលទ្ធផលក៏ដោយ គេអាចត្រូវការឲ្យមានហិរញ្ញប្បទានខ្លះៗជាមុន។ តើធ្វើបែបណាដើម្បីទទួលបានហិរញ្ញប្បទានជាមុន គឺជាប្រធានបទមួយដែលគួរតែពិចារណាផងដែរ។ នៅក្នុងករណីដែលមានអង្គភាពផ្តល់ហិរញ្ញប្បទានខុសគ្នា។ ក្នុងករណីនោះ យុទ្ធសាស្ត្រក៏គួរផ្តល់ទិសដៅសម្រាប់ណែនាំអំពីរបៀបទទួលបានមូលនិធិដែលផ្អែកតាមលទ្ធផលផងដែរ។

ជាតុផ្សំដទៃទៀតនឹងគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រនេះ ហើយគោលនយោបាយ និងវិធានការនានា ដូចជា ការវិភាគជាបន្ថែមអំពីបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ អត្ថប្រយោជន៍ដែលព្រៃឈើផ្តល់ឲ្យ ថ្លៃចំណាយ និងផលចំណេញ ដែល REDD+ ផ្តល់ឲ្យ ដែលរួមទាំង ថ្លៃឱកាស ការវិភាគអំពីច្បាប់ និងគោលនយោបាយនានាដែលមានស្រាប់ និយមន័យព្រៃឈើ បច្ចេកវិទ្យាដែលមានស្រាប់សម្រាប់ពិនិត្យតាមដានព្រៃឈើ។ល។

ការងាររបស់ក្រុមបច្ចេកទេសអាចបង្កើតអនុសាសន៍អំពីជាតុផ្សំទាំងអស់ខាងលើ ប៉ុន្តែដោយសារតែមានកិច្ចការយ៉ាងច្រើន ដូច្នេះគេអាចចំណាយពេលពីរឆ្នាំ និងអាចយូរជាងនេះ ដូចជាក្នុងករណី វិសោធនកម្មច្បាប់ដែលមានស្រាប់ ឬ ច្បាប់ថ្មី គឺជាតម្រូវការ ដើម្បីបង្កើតមូលនិធិ REDD+។ ដូច្នេះ គេគួរតែបង្កើតផែនការដែលចែងអំពីជាតុផ្សំខុសៗគ្នា ជាមួយចំណុចគោលនានា ដើម្បីអាចឲ្យមានការពិនិត្យតាមដានដំណើរការនេះបានជិតស្និទ្ធ។

ការផ្តល់មូលនិធិសម្រាប់កសាងយុទ្ធសាស្ត្រជាតិ **REDD+**
ការបង្កើតយុទ្ធសាស្ត្រនេះ អាចទទួលការគាំទ្រពីក្របខ័ណ្ឌមួយចំនួន ដូចជា UN-REDD, CAM-REDD និង FCPF។ល។

ការផ្តល់មូលនិធិក្រៅក្របខ័ណ្ឌនៃការកសាងយុទ្ធសាស្ត្រជាតិ **REDD+**
ក្នុងពេលដែលជាតុផ្សំខុសៗគ្នានៃយុទ្ធសាស្ត្រនេះកំពុងស្ថិតក្នុងការរៀបចំ ហើយសកម្មភាពនិងថ្លៃចំណាយពាក់ព័ន្ធបង្ហាញឲ្យឃើញកាន់តែច្បាស់ វាកាន់តែផ្តល់ភាពទាក់ទាញដល់ម្ចាស់ជំនួយដើម្បីផ្តល់ការគាំទ្រ ដោយសារការយកចិត្តទុកដាក់ជាច្រើនរបស់សហគមន៍អន្តរជាតិបច្ចុប្បន្ននេះ គឺលើសកម្មភាពនានាដែលបង្កើតឲ្យមានការកាត់បន្ថយការបំភាយដែលអាចវាស់វែងបាន។

ជំហានខាងមុខ
ជាមួយការអនុម័តពីក្រុមការងារពិសេស ក្រុមបច្ចេកទេសទាំងបួនអាចត្រូវអញ្ជើញឲ្យចូលរួមដើម្បីលើកស្នើផែនការការងារមួយជាមួយការកំណត់ចំណុចគោលនានាសម្រាប់ការងារនៅក្នុងជំពូកនានា។
តើក្រុមការងារពិសេសឯកភាពក្នុងការបង្កើតក្រុមស្នូលមួយដែលមានតំណាងមកពីស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាមួយក្រុមបច្ចេកទេស និងក្រោមការទាក់ទងជិតស្និទ្ធជាមួយក្រុមការងារពិសេស ដែលគាំទ្រដោយអ្នកជំនាញការ និងអាចទីប្រឹក្សា ដែរឬទេ?

---

[7] សេចក្តីសម្រេច 10/CP.19 ស្តីពីការសម្របសម្រួលនូវការគាំទ្រដល់ REDD+ វាក្យខណ្ឌ 2 អញ្ជើញប្រទេសនានាឲ្យចាត់តាំងអង្គភាពរបស់ខ្លួនដើម្បីស្វែងរក និងទទួលការទូទាត់ដែលផ្អែកលើលទ្ធផល ដែលស្របគ្នាជាមួយគំរូប្រតិបត្តិការណាមួយជាក់លាក់អំពីអង្គភាពហិរញ្ញប្បទានដែលផ្តល់ការគាំទ្រដល់ប្រទេសទាំងនោះ។